**ក្រុមការងារបច្ចេកទេសត្រីភាគី ដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨**

**សូមគោរពជូន**

**ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការប្រឹក្សាការងារ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី ដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨។

**យោង ៖** សេចក្តីសម្រេចលេខ ០២៤/១៧ ក.ប/ស.ស.រ.ខ.ល ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសត្រីភាគី ដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** និងជា **ប្រធានគណៈកម្មការប្រឹក្សាការងារ** មេត្តាជ្រាបថា ក្រុមការងារបច្ចេកទេសត្រីភាគី ដែលមានតំណាងភាគីកម្មករនិយោជិតចំនួន ១៦រូប តំណាងភាគីនិយោជកចំនួន ១៦រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន ១៦រូប បានប្រជុំពិភាក្សាដោយឈរលើគោលការណ៍ប្រជាធិបតេយ្យ ស្មារតីមិត្តភាព សហប្រតិបត្តិការ តម្លាភាព និង ឈ្នះ-ឈ្នះ អស់រយៈពេល ០៣ថ្ងៃ ស្មើនឹង ០៤លើក ដូចខាងក្រោម៖

- លើកទី១ នៅព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ ប្រជុំពិភាក្សាអំពីបម្រែបម្រួលលក្ខណវិនិច្ឆ័យទាំង៧ រួមមានស្ថានភាពគ្រួសារ អត្រាអតិផរណា ចំណាយក្នុងការរស់នៅ ផលិតភាព ភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាពទីផ្សារការងារ កម្រិតចំណេញរបស់វិស័យ ក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨។
- លើកទី២ នៅរសៀលថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ បន្តប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី។
- លើកទី៣ នៅរសៀលថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី។
- លើកទី៤ នៅរសៀលថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧ ប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី។

ឆ្លងតាមការប្រជុំជាច្រើនលើកនេះ ក្រុមការងារបច្ចេកទេសសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

**ក- ជំហររួមរបស់ភាគីទាំងបី**

១. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានរក្សាក្រុមការងារបច្ចេកទេសត្រីភាគី ដែលមានសមាសភាពស្មើគ្នា ដើម្បីពិភាក្សាលម្អិតលើទិន្នន័យ ស្ថិតិ និងហេតុផលនៃការប្រែប្រួលលក្ខណវិនិច្ឆ័យទាំង៧ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជាសម្រាប់ឆ្នាំ ២០១៨។

២. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអំពាវនាវដល់ម្ចាស់ផ្ទះជួលកុំឱ្យដំឡើងថ្លៃឈ្នួលផ្ទះចំពោះកម្មករនិយោជិតក្នុងឆ្នាំ២០១៨នេះ។

៣. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានបញ្ចុះថ្លៃទឹកស្អាត និងថ្លៃអគ្គិសនីដែលប្រើប្រាស់ដោយកម្មករនិយោជិត។ ពោលគឺ ចំពោះថ្លៃទឹកស្អាត ដោយចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ តទៅ ម្ចាស់ផ្ទះជួលនឹងលក់ឱ្យកម្មករនិយោជិត ត្រឹមតែ ៨០០៛ ប៉ុណ្ណោះក្នុង១ម៉ែត្រគូប។ ចំពោះថ្លៃអគ្គិសនីវិញ គឺត្រឹមតែ ៤១០៛ ប៉ុណ្ណោះចំពោះការប្រើប្រាស់ថាមពលក្រោម ៥០គីឡូវ៉ាត់ម៉ោង។

៤. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានសម្រេចផ្តល់សេវារថយន្តក្រុងសាធារណៈ សម្រាប់ដឹកកម្មករនិយោជិតដោយឥតគិតថ្លៃ សម្រាប់រយៈពេល ២ឆ្នាំ ចាប់ពីខែសីហា ឆ្នាំ២០១៧ ដល់ខែសីហា ឆ្នាំ២០១៩។

៥. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលមានផ្ទៃពោះលើសពី ៣ខែ បានចេញមុនម៉ោងការងាររបស់ខ្លួនចំនួនយ៉ាងតិច ១៥នាទី ដើម្បីគាំពារសុខុមាលភាពកម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ និងទារកក្នុងផ្ទៃ។

៦. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ចំពោះស្ត្រីជាកម្មការិនីមានផ្ទៃពោះ ដោយបានសម្រេចផ្តល់ប្រាក់ខែ ១២០% ក្នុងរយៈពេលសម្រាកឆ្លងទន្លេបីខែ។

៧. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាតឱ្យបងប្អូនកម្មករនិយោជិតដែលជាស្ត្រីខ្មែរឥស្លាម អាចប្រើប្រាស់សម្លៀកបំពាក់តាមបែបប្រពៃណីឥស្លាមមកបំពេញការងារ វៀរលែងតែប៉ះពាល់ដល់សុវត្ថិភាពការងាររបស់កម្មករនិយោជិតដែលជាស្ត្រីខ្មែរឥស្លាម។

៨. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីដែលបានសម្រាលកូន ទោះបីក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធ ទោះបីកូននោះកើតរស់ ឬស្លាប់ក៏នៅតែទទួលបានប្រាក់ឧបត្ថម្ភគាំពារ។ ក្នុងនោះ បើសម្រាលបានកូនមួយនាក់ នឹងទទួលបានប្រាក់ឧបត្ថម្ភ ៤០ម៉ឺនរៀល កូនភ្លោះពីរនាក់ ទទួលបាន ៨០ម៉ឺនរៀល និងកូនភ្លោះបីនាក់ ទទួលបាន ១២០ម៉ឺនរៀល។ អត្ថប្រយោជន៍នេះនឹងអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

៩. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលអនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់ទទួលបានការពិនិត្យព្យាបាលជំងឺនៅមន្ទីរពេទ្យរដ្ឋដោយមិនគិតថ្លៃចាប់ពីឆ្នាំ២០១៨ តទៅ។

១០. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានបន្តមិនយកពន្ធលើអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត។

១១. សូមថ្លែងអំណរគុណដល់អង្គការអន្តរជាតិខាងការងារ(ILO) ដែលបានផ្តល់ជំនួយបច្ចេកទេស និងលើកកម្ពស់សមត្ថភាពដល់ត្រីភាគី ឱ្យបានកាន់តែយល់ច្បាស់អំពីយន្តការ និងលក្ខណវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា។

១២. សូមថ្លែងអំណរគុណដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានរៀបចំបន្ទប់ប្រជុំ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់ភាគីកម្មករនិយោជិត និងភាគីនិយោជក ប្រើប្រាស់ក្នុងកិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំទ្វេភាគី។

១៣. បានរៀបចំចងក្រងក្រមសីលធម៌សម្រាប់អនុវត្តក្នុងកិច្ចប្រជុំ ដោយភាគីនីមួយៗត្រូវប្រកាន់ខ្ជាប់នូវស្មារតីអត់ធ្មត់ អធ្យាស្រ័យ និងសុឆន្ទៈ ព្រមទាំងប្រើប្រាស់ហេតុផល និងទឡ្ហីករណ៍សមស្របដែលពាក់ព័ន្ធនឹងបម្រែបម្រួលលក្ខណវិនិច្ឆ័យទាំង៧ នៃការដំឡើងប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨។

១៤. បានកំណត់យកវិធីសាស្ត្រ នៃការអនុម័តសេចក្តីសម្រេចរបស់ក្រុមការងារបច្ចេកទេសត្រីភាគីដោយប្រើយន្តការកុងសង់ស៊ីស។ ក្នុងករណីមិនមានកុងសង់ស៊ីសលើតួលេខ ឬអត្រាកំណើនណាមួយត្រូវបោះឆ្នោតជាសម្ងាត់ដើម្បីស្ទាបស្ទង់លើការគាំទ្រតួលេខ ឬអត្រាកំណើនដែលទទួលបានពីគ្រប់ភាគី ដើម្បីធ្វើជារបាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជ្រាប និងធ្វើការកោះប្រជុំគណៈកម្មការប្រឹក្សាការងារពិនិត្យពិភាក្សា។

១៥. បានពិភាក្សាអំពីអត្រាបម្រែបម្រួលលក្ខណវិនិច្ឆ័យទាំង៧ ក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨។

ឆ្លងតាមការពិភាក្សាគ្នា អង្គប្រជុំបានបង្រួមគម្លាតនៃតួលេខរៀងខ្លួន និងបានបោះឆ្នោតស្ទាបស្ទង់លើតួលេខរបស់ភាគីទាំងបីស្របទៅតាមនីតិវិធីដែលបានឯកភាពគ្នានៅមុនពេលចរចា ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តួលេខចំនួន ១៧០ដុល្លារអាមេរិក របស់ភាគីតំណាងកម្មករនិយោជិត ទទួលបានសំឡេងឆ្នោត ១៥សំឡេង លើ ៤៧សំឡេង
- តួលេខចំនួន ១៦២ដុល្លារអាមេរិក របស់ភាគីតំណាងនិយោជក ទទួលបានសំឡេងឆ្នោត ១៦សំឡេង លើ ៤៧សំឡេង
- តួលេខចំនួន ១៦៥ដុល្លារអាមេរិក របស់ភាគីតំណាងរាជរដ្ឋាភិបាល ទទួលបានសំឡេងឆ្នោត ១៦សំឡេង លើ ៤៧សំឡេង។

ក្រៅពីការអនុម័តទៅលើតួលេខប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៨ ភាគីនីមួយៗបានភ្ជាប់ជាមួយនូវជំហរដោយឡែករបស់ខ្លួន ដូចខាងក្រោម៖

## ខ- ជំហរ និងសំណើរបស់ភាគីតំណាងកម្មករនិយោជិត (សហជីព)

១. សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានឱ្យនិយោជកបង់ភាគទាន ប.ស.ស ផ្នែកថែទាំសុខភាពចំនួន ១.៣ភាគរយ ជំនួសកម្មករនិយោជិត ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

២. ភាគីតំណាងកម្មករនិយោជិត នឹងធ្វើសំណើជាឯកតោភាគីរៀងៗខ្លួនទៅកាន់សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងបណ្តាប្រទេសដទៃផ្សេងទៀត ក៏ដូចជាទៅកាន់ម្ចាស់ម៉ាកនានា ឱ្យកាន់តែបើកចំហទីផ្សារសម្រួលលក្ខខណ្ឌពាណិជ្ជកម្មសម្រាប់ទំនិញពីកម្ពុជា និងបង្កើនការបញ្ជាទិញពីកម្ពុជា។

៣. សូមរាជរដ្ឋាភិបាលបន្តពង្រីកបណ្តាញអគ្គិសនី បណ្តាញទឹកស្អាតដែលមានតម្លៃទាបឱ្យបាននៅទូទាំងប្រទេស។

៤. សូមរាជរដ្ឋាភិបាលបន្តអនុវត្តច្បាប់ភតិសន្យាពិសេស (ច្បាប់ជួលបន្ទប់) ឱ្យបានម៉ឺងម៉ាត់ជៀសវាងការដំឡើងថ្លៃ។

៥. សូមរាជរដ្ឋាភិបាលរៀបចំមធ្យោបាយធ្វើដំណើរសម្រាប់បងប្អូនកម្មករនិយោជិតឱ្យបានសមរម្យជៀសវាងគ្រោះថ្នាក់ការងារ។

៦. សូមរាជរដ្ឋាភិបាលរៀបចំយន្តការគ្រប់គ្រងលើការទូទាត់សំណងឱ្យបានត្រឹមត្រូវជូនកម្មករនិយោជិត ក្នុងករណីរោងចក្របិទទ្វារ (ថៅកែរត់ចោល)។

## គ- សំណូមពររបស់ភាគីតំណាងនិយោជកចំពោះរាជរដ្ឋាភិបាល

១. សុំពន្យារសុពលភាពការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរបស់រោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងកាបូប សម្រាប់រយៈពេលប្រាំឆ្នាំ (ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២)។

២. សុំកាត់បន្ថយកម្រៃគ្រប់គ្រងការនាំចេញ(EMF) ចំនួនពាក់កណ្តាល។ កម្រៃគ្រប់គ្រងការនាំចេញនេះ កាលពីមុនត្រូវបានហៅថា កម្រៃគ្រប់គ្រងកូតានាំចេញ ដែលត្រូវបានដាក់ចេញក្នុងអំឡុងសម័យកូតា។ ប្រទេសកម្ពុជាលែងស្ថិតនៅក្នុងការដាក់កំហិតកូតាណាមួយទៀតហើយចាប់តាំងពីការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០៤។

៣. សុំកាត់បន្ថយកម្រៃត្រួតពិនិត្យកាំកុងត្រូល មកស្មើនិងតម្លៃកម្រៃបែបបទគយ។

៤. ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** និងជា **ប្រធានគណៈកម្មការប្រឹក្សាការងារ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** និងជា **ប្រធានគណៈកម្មការប្រឹក្សាការងារ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧

| តំណាងភាគីកម្មករនិយោជិត | តំណាងភាគីនិយោជក | តំណាងភាគីរាជរដ្ឋាភិបាល |
|---|---|---|
| **បណ្ឌិត ជួន មុំថុល** | **Mr. Enjoy Ho** | **ឯ.ឧ ហេង សួរ** |
| សហព័ន្ធសហជីពខ្មែរ | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

លោក អាត់ ធន់

សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

កញ្ញា ងី ស្រីមុំ

សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

ឯ.ឧ ទេស រុក្ខាផល

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លោក សៀង សម្បត្តិ

សហព័ន្ធសហជីពមិត្តភាពកម្មករ

លោក អៀម រ៉ាវី

សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

ឯ.ឧ កុយ ទេពដារាវុធ

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លោក ហ្វា សាលី

សម្ព័ន្ធសហជីពជាតិ

Mr. Sam Leung

(លោក តោ ដារ៉ាវិទ្ធ)

សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

លោក អ៊ឹក ចាន់ធូ

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លោកស្រី យ៉ាង សុភ័ណ្ឌ

សម្ព័ន្ធសហជីពកម្ពុជា

លោក ឡុង ហ៊ាង

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

លោក ប៉ុល ចាន់ដារ៉ា

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លោក សោម អូន

សភាសម្ព័ន្ធសហជីពជាតិកម្ពុជា

លោក លី តេកហេង

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

លោក អ៊ុន ចំរើន

វិទ្យាស្ថានជាតិស្ថិតិ

លោក ប៉ាវ ស៊ីណា

សម្ព័ន្ធសហជីពចលនាកម្មករ

លោក តាំង ម៉េង

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

លោក នូ ភិរុណា

វិទ្យាស្ថានជាតិស្ថិតិ

**លោក ម៉ាន់ សេងហាក់**
សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

**លោក សួង ហួត**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**លោក គិត សុវណ្ណារិទ្ធ**
ធនាគារជាតិនៃកម្ពុជា

**លោកស្រី ទេព គឹមវណ្ណារី**
សហព័ន្ធសហជីពឯករាជ្យកម្ពុជា

**Ms. Mercedes CHA**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**លោក គួច សុមាន**
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

**លោក គឹម ចាន់សំណាង**
សហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន

**លោក អ៊ិន ម៉េង**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**លោក ប៉ែន នរៈវុធ**
បេឡាជាតិរបបសន្តិសុខសង្គម

**លោក សាត់ ឈាងហួ**
សហភាពជាតិកម្ពុជាការពារកម្មករ

**លោក គិម ពេជ្រជា**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**លោក ណៅ វ៉ាន់ឌី**
លេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា

**លោក ឈិន សូនី**
សហព័ន្ធសហជីពការងារសេវាកម្មកម្ពុជា

**លោក អ៊ុំ វិសាល**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**លោក ប៊ី ពិទូរ្យ**
ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**លោក ពុធ សុវណ្ណ**
សហព័ន្ធសហជីពដើម្បីកម្មករ

**លោកស្រី ហួត សាន់នី**
ក្រុមហ៊ុនព្រូដិនសលកម្ពុជា

**លោកស្រី គួច ច័ន្ទកេសី**
ក្រសួងពាណិជ្ជកម្ម

**លោក វ័ន្ធ មីនា**

សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភណ្ឌកាត់ដេរកម្ពុជា

**លោកស្រី ម៉ោញ ច័ន្ទកេសី**

ក្រុមហ៊ុន ខេមបូហុងស៊ីង

**លោក ជា សុភ័ក្ត**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**លោក ហេង ប៊ុនឈុន**

សហភាពសហជីពជាតិឯករាជ្យកម្ពុជា

**លោក ងាប ឆេងលាភ**

ក្រុមហ៊ុន ស្រាបៀរកម្ពុជា ខេមប្រ៊ូវ

**លោក ហ៊ឹម ផានិត**

មជ្ឈមណ្ឌលផលិតភាពជាតិ

**លោក ចាប សុភាព**

ក្រុមហ៊ុន មីនេបៀ ខេមបូឌា

**លោក វ៉ន សុវត្ថា**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា